- **ប្រសិនបើដងកុងតាក់ ELB មិនអាចកំណត់ឡើងវិញបានទេ ទោះបីជាអ្នករុញវាឡើងលើ ឬប្រសិនបើវាធ្លាក់ចុះមកវិញភ្លាមៗចុះក្រោមអំឡុងពេលប្រតិបត្តិការក៏ដោយ សូមកុំប្រើម៉ាស៊ីនទឹកក្តៅ ហើយទាក់ទងភ្នាក់ងារចែកចាយជាបន្ទាន់ ដើម្បីជៀសវាងគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ដូចជាការខូចខាតទ្រព្យសម្បត្តិ របួសធ្ងន់ធ្ងរ ឬការស្លាប់។ កុំជួសជុលដងកុងតាក់ ELB ដោយកម្លាំងឬបិតស្តូតស្តួតជាដើម។ល។**
- **កុំលូកម្រាមដៃ ឬវត្ថុផ្សេងទៀតទៅក្នុងម៉ាស៊ីនទឹកក្តៅទឹកត្រជាក់អគ្គិសនីតាមផ្ទះ ដើម្បីជៀសវាងគ្រោះថ្នាក់ដល់រាងកាយ និងការឆក់ចរន្តអគ្គិសនី។**
- **កុំផ្លាស់ប្តូរក្បាលទឹកផ្កាឈូក ទុយោទឹកផ្កាឈូក ឬផ្នែកផ្សេងទៀតនៃឧបករណ៍នេះដោយគ្រឿងបន្លាស់ក្រៅពីគ្រឿងបន្លាស់សុទ្ធល្អ។**
  - គ្រឿងបន្លាស់សម្រាប់ម៉ូដែលផ្សេងទៀតនឹងមិនត្រូវនឹងម៉ូដែលនេះទេ ហើយអាចបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់។



- **មិនត្រូវជាប់ទឹកចូលក្នុងឧបករណ៍ ឬដាក់កន្សែងទទឹកសើមនៅលើឧបករណ៍ ជៀសវាងការប៉ះពាល់ជាមួយផ្នែកចំហផ្សេងៗជាដើម ដើម្បីការពារការបញ្ចេញផ្សែង ការឆាប់ឆេះ ភ្លើងចេះ និងការឆក់ចរន្តអគ្គិសនី។**
- **ឧបករណ៍នេះមិនត្រូវប្រើសម្រាប់ការផ្តល់ផ្តងទឹកសម្រាប់បរិភោគទេទេ។**

- **ឧបករណ៍នេះត្រូវតែភ្ជាប់ខ្សែដី។**
  - ការភ្ជាប់ខ្សែដីមិនត្រឹមត្រូវអាចបង្កឱ្យមានការឆក់ចរន្តអគ្គិសនី។

- **ឈប់ប្រើប្រាស់ឧបករណ៍ នៅពេលដែលមានភាពមិនប្រក្រតី / ការខូចខាតណាមួយកើតឡើង ហើយ "បិទ" ឧបករណ៍បំបែកសៀគ្វីតូច (MCB) ។**
  (ហានិភ័យនៃផ្សែង / ភ្លើងឆេះ / ការឆក់អគ្គិសនី / ការលាកទឹកក្តៅ)
  ឧទាហរណ៍នៃភាពមិនប្រក្រតី / ការខូចខាត:
  - ដងកុងតាក់ ELB មិនអាចកំណត់ឡើងវិញបានទេ។ សូមអានចំនុចលេខ 3 ។ "ប្រតិបត្តិការសាកល្បង" នៅទំព័រ KH15 ។
  - ក្លិនឆេះ ឬផ្សែងត្រូវបានរកឃើញអំឡុងពេលប្រតិបត្តិការ។
  - បន្ទះខាងមុខ / បន្ទះខាងក្រោយខូចទ្រង់ទ្រាយ ឬក្តៅខុសពីធម្មតា។
  - សីតុណ្ហភាពទឹកនៅច្រកចេញឡើងក្តៅខ្លាំង ហើយមិនអាចគ្រប់គ្រងបានដោយប្រើប៊ូតុង - និង + នៅផ្ទាំងបញ្ជា។
    → ទាក់ទងភ្នាក់ងារចែកចាយដែលទទួលសិទ្ធិរបស់អ្នកជាបន្ទាន់សម្រាប់ការថែទាំ / ការជួសជុល។

- **បិទឧបករណ៍បំបែកសៀគ្វីតូច (MCB) មុនពេលធ្វើការជួសជុលណាមួយ ដើម្បីជៀសវាងគ្រោះថ្នាក់ពីការឆក់ចរន្តអគ្គិសនី។**
- **នៅពេលដែលមានរន្ទះ / ផ្គរលាន់ សូម "បិទ" ឧបករណ៍បំបែកសៀគ្វីខ្នាតតូច (MCB) ជាមុន ដើម្បីបង្ការម៉ាស៊ីនទឹកក្តៅទឹកត្រជាក់អគ្គិសនីតាមផ្ទះពីការខូចខាតដែលអាចកើតមាន។**
- **ត្រួតពិនិត្យមើលលើ ELB ដែលដំឡើងមកស្រាប់ (មួយខែម្តង) ដើម្បីជៀសវាងគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ដូចជាការខូចខាតទ្រព្យសម្បត្តិ ការរងរបួសធ្ងន់ធ្ងរ ឬការស្លាប់។ សូមអានចំណុចលេខ 3 ។ "ប្រតិបត្តិការសាកល្បង" នៅទំព័រ KH15 ។**
- **រាល់ពេលដែលទឹកផ្កាឈូកត្រូវបាន 'បើក' សូមពិនិត្យមើលសីតុណ្ហភាពទឹកដោយដៃមុនពេលងូតទឹក។**
- **នៅពេលដែលទឹកផ្កាឈូកត្រូវបានប្រើប្រាស់ដោយនរណាម្នាក់ដូចជា កុមារ មនុស្សចាស់ មនុស្សឈឺ និងអ្នកពិការរាងកាយ អ្នកដែលទទួលខុសត្រូវចំពោះសុវត្ថិភាពរបស់ពួកគេត្រូវបាន ស្នើសុំអោយមានការយកចិត្តទុកដាក់ខ្ពស់ និងពិនិត្យមើលសីតុណ្ហភាពទឹកផ្កាឈូកដោយប្រើដៃយូរៗម្តង។**



- **យកចិត្តទុកដាក់លើសីតុណ្ហភាពទឹកផ្កាឈូកនៅពេលបន្ថយបរិមាណទឹក។**
  - សីតុណ្ហភាពទឹកផ្កាឈូកនឹងឡើងក្តៅខ្លាំង ប្រសិនបើអ្នកប្រើប្រាស់ហូរទឹកទាបពេក។
- **ឧបករណ៍នេះមិនត្រូវបានប្រើប្រាស់សម្រាប់បុគ្គល (រួមបញ្ចូលទាំងកុមារ) ដែលអាចកាត់បន្ថយសមត្ថភាពរាងកាយ ឌួរក្បាល ឬផ្លូវចិត្ត ឬខ្វះបទពិសោធ និងចំណេះដឹង លុះត្រាតែពួកគេត្រូវបានផ្តល់ការត្រួតពិនិត្យ ឬការណែនាំទាក់ទងនឹងការប្រើប្រាស់ឧបករណ៍ដោយអ្នកដែលទទួលខុសត្រូវសម្រាប់សុវត្ថិភាពរបស់ពួកគេ។ កុមារគួរតែត្រូវបានត្រួតពិនិត្យមើលដើម្បីធានាថាពួកគេមិនលេងជាមួយឧបករណ៍នេះ។**

⚠ បម្រុងប្រយ័ត្ន



- **កុំប្រើបង់ហ្សែន សារធាតុរាវ ភ្នាក់ងារកម្ចាត់ស្នាមប្រឡាក់ ជាដើម សម្រាប់គោលបំណងសម្អាត ដើម្បីជៀសវាងការបញ្ចេញផ្សែង ការឆាបឆេះ ភ្លើងឆេះ និងគ្រោះថ្នាក់ដោយការឆក់ចរន្តអគ្គិសនី។**
- **ជៀសវាងការប្រើប្រាស់ទឹកខ្ងក់ ព្រោះវាអាចប៉ះពាល់ដល់ដំណើរការកម្តៅ និងសមាសធាតុផ្សេងទៀត។**



- **កុំខ្ជប់ក្បាលទឹកផ្កាឈូកដោយដៃ កន្សែង ឬបត់ទុយោ។ អត្រាហូរទឹកនឹងធ្លាក់ចុះ ហើយសីតុណ្ហភាពទឹកអាចនឹងឡើងក្តៅខ្លាំង។**

- **ដើម្បីជៀសវាងគ្រោះថ្នាក់ដោយសារការកំណត់ឡើងវិញដោយមិនយកចិត្តទុកដាក់នៃការកាត់ផ្តាច់កម្តៅ ឧបករណ៍នេះមិនត្រូវផ្គត់ផ្គង់តាមរយៈឧបករណ៍ប្តូរខាងក្រៅ ដូចជាឧបករណ៍កំណត់ពេលវេលា ឬភ្ជាប់ទៅសៀគ្វីដែលត្រូវបានបើក និងបិទជាប្រចាំដោយឧបករណ៍ប្រើប្រាស់នោះទេ។**

- **សូមជ្រាកដថា O-រីងមិនត្រូវបានដោះចេញទេ ហើយស្ថិតនៅឆ្ងាយពីបំណែកដទៃដើម្បីជៀសវាងការលេចធ្លាយទឹក។**
- **ចុចដងរុញបើក-បិទ មុន និងក្រោយពេលងូតទឹកម្តងៗ។**
  - ចុចតែប៊ូតុងបើក-បិទប៉ុណ្ណោះ។
  - ចូរកុំទាញ។
  - ចូរកុំ "បើក" និង "បិទ" វ៉ាល់បើកបិទទឹកមេ ដើម្បីដំណើរការម៉ាស៊ីនទឹកក្តៅទឹកត្រជាក់តាមផ្ទះ ដើម្បីជៀសវាងការខូចខាតណាមួយដែលអាចកើតមានឡើង។



គ្រឿងបន្លាស់

ការវេចខ្ចប់៖	ធាតុរួមបញ្ចូល៖		
 ការវេចខ្ចប់ក្បាលទឹកផ្កាឈូក	 ក្បាលទឹកផ្កាឈូក (1 ឈុត)		
 ការវេចខ្ចប់ធ្នើរព្យួរទឹកផ្កាឈូក	 ទុយោទឹកផ្កាឈូក (1 ឈុត)	 x 2 ទម្របង្កាន់ដៃ (2 ឈុត)	 ឈុតធ្នើរព្យួរទឹកផ្កាឈូក (1 ឈុត)
 ការវេចខ្ចប់តួតម្រងចម្រោះ	 បង្គំតួតម្រងចម្រោះ (1 ឈុត)	 ការវេចខ្ចប់កៅស៊ូកង (1 ដុំ)	 តារាងការប្រុងប្រយ័ត្ននៃការបង្គំតួតម្រងចម្រោះ (1 ដុំ)
 បង្កាន់ដៃអូសទៅមក	 បង្កាន់ដៃអូសទៅមក (1 ដុំ)		
 ការវេចខ្ចប់ការតឿង	 x 6 តាកេងញ៉ាំង (6 ដុំ)	 x 2 ការវេចខ្ចប់កៅស៊ូកង (2 ដុំ)	 x 6 វីស (6 ដុំ)

ការកំណត់អត្តសញ្ញាណគ្រឿងបន្លាស់



ការពិពណ៌នាអំពីអេក្រង់ LCD & ផ្ទាំងបញ្ជា

អេក្រង់ LCD និងផ្ទាំងបញ្ជា
DH-4UD1 & DH-3UD1



ផ្ទាំងបញ្ជា
DH-4US1 & DH-3US1



U-Mode (DH-4UD1 & DH-3UD1)

1. U-Mode ដំណើរការដើម្បីផ្តល់នូវបទពិសោធន៍បន្ទាប់ពីងូតទឹកផ្សេងៗគ្នាអាស្រ័យតាមបុគ្គល។
2. U-Mode មានបីជម្រើស
   a) Cool Down
   - អ្នកប្រើប្រាស់មានអារម្មណ៍ស្រស់ស្រាយក្រោយពេលងូតទឹក។
   - សីតុណ្ហភាពរាងកាយត្រជាក់បន្ទាប់ពីងូតទឹករួច។

   b) Warm Up
   - អ្នកប្រើប្រាស់មានអារម្មណ៍កក់ក្តៅ និងជាសុកភាពបន្ទាប់ពីងូតទឹករួច។
   - សីតុណ្ហភាពរាងកាយនឹងឡើងក្តៅបន្តិចបន្ទាប់ពីងូតទឹករួច។

   c) Hot & Cool
   - ការផ្លាស់ប្តូរការងូតទឹកក្តៅ ទៅការងូតទឹកត្រជាក់ជួយដល់ការពន្លឿនការពង្រីក / ការបង្រួមសរសៃឈាម ធ្វើឱ្យចរន្តឈាមរត់បានប្រសើរឡើង។
   - អ្នកប្រើប្រាស់មានអារម្មណ៍ធូរស្រាល និងស្រស់ស្រាយបន្ទាប់ពីងូតទឹករួច។

   ចំណាំ៖ សូមជ្រាបថា ប្រសិទ្ធិភាពគឺខុសគ្នាទៅតាមបុគ្គល។

⚠ បម្រុងប្រយ័ត្ន

សូមបញ្ឈប់ការប្រើប្រាស់មុខងារ U-Mode ជាបន្ទាន់ ប្រសិនបើមានអារម្មណ៍មិនស្រួលក្នុងអំឡុងពេលប្រើប្រាស់។

ចំណាំ៖ សម្រាប់របៀបប្រើប្រាស់មុខងារ សូមមើលទំព័រ KH7

U-Memory (DH-4UD1 & DH-3UD1)

1. U-Memory អនុញ្ញាតឱ្យអ្នកប្រើប្រាស់រក្សាទុកទិន្នន័យរួមបញ្ចូលគ្នាមួយពីមុខងារដូចខាងក្រោម៖
   a) មុខងាររបស់ U-Mode ។
   b) សីតុណ្ហភាពទឹកផ្កាឈូក។
2. U-Memory ផ្តល់នូវការរួមបញ្ចូលទិន្នន័យបីផ្សេងៗគ្នាដែលអាចត្រូវបានរក្សាទុក។ (ប៊ូតុង U-Memory [1 / 2 / 3])

   ចំណាំ៖ សម្រាប់របៀបប្រើប្រាស់មុខងារ សូមមើលទំព័រ KH8

របៀបប្រើប្រាស់ម៉ាស៊ុនទឹកក្តៅទឹកត្រជាក់អគ្គិសនីតាមផ្ទះ

របៀបប្រើប្រាស់

1. កាច់ "បើក" វាល់ទឹកមេ។
2. មួល "បើក" ឧបករណ៍ប់បៃកសៀគ្វីខ្នាតតូច (MCB) និងកុងតាក់ DP បើក/បិទ (ប៉ូលពីរ) ។
3. រុញដងកុងតាក់ ELB ឡើងលើ ប្រសិនបើវាធ្លាក់ចុះក្រោម។
4. បង្វិលក្បាលមួលកម្រិតបរិមាណទឹកតាមទ្រនិចនាឡិកា។
   - ការបង្វិលវាតាមទ្រនិចនាឡិកា បង្កើនបរិមាណទឹក ដូច្នេះសីតុណ្ហភាពទឹកថយចុះ។
   - ការបង្វិលវាបញ្ច្រាស់ទ្រនិចនាឡិកា ធ្វើឱ្យបរិមាណទឹកថយចុះ ដូច្នេះសីតុណ្ហភាពទឹកកើនឡើង



ELB៖ ស្ថានភាព បើក



ELB៖ ស្ថានភាព បិទ

5. ចុចដងរុញបើក-បិទ។
   a) ទឹកនឹងហូរចេញពីក្បាលទឹកផ្កាឈូក។
   b) ភ្លឺងពេលដំណាលគ្នា
      DH-4UD1 & DH-3UD1 - អេក្រង់ LCD បំភ្លឺ និងបង្ហាញ ភ្លើងសញ្ញាសីតុណ្ហភាព ភ្លើងសញ្ញានាឡិកា និងក្បាលទឹកផ្កាឈូក។
      (នៅពេលថាមពលបើក សីតុណ្ហភាពឡើងដល់ 38°C)
      DH-4US1 & DH-3US1 - ភ្លើង ELB នឹងភ្លឺឡើង។
   c) ដើម្បីបញ្ឈប់ហូរទឹក សូមចុចដងរុញបើក-បិទ ម្តងទៀត។
   d) ដងនេះគ្រប់គ្រងទាំងការផ្គត់ផ្គង់ទឹក និងអគ្គិសនីរបស់ឧបករណ៍នេះ



ត្រូវប្រាកដថារុញតែនៅចំកណ្តាលនៃប៊ូតុងបើក-បិទ ប៉ុណ្ណោះ។

⚠ បម្រុងប្រយ័ត្ន

ចុចដងរុញបើក-បិទ មុន និងក្រោយពេលងូតទឹកម្តងៗ។
ចុចតែដងរុញបើក-បិទប៉ុណ្ណោះ។ ចូរកុំទាញ។
ចូរកុំ "បើក" និង "បិទ" វាល់បើកបិទទឹកមេ ដើម្បីដំណើរការម៉ាស៊ុនទឹកក្តៅទឹកត្រជាក់តាមផ្ទះ ដើម្បីជៀសវាងការខូចខាតណាមួយដែលអាចកើតមានឡើង។

6. ជ្រើសរើសទឹកផ្កាឈូកដែលពេញចិត្តដោយមួលដងមួលជ្រើសរើសប្រភេទទឹកផ្កាឈូក។





ចំណាំ៖
នៅពេលបញ្ឈប់រំហូរទឹក ឬផ្លាស់ប្តូរការជ្រើសរើសជ័សរើសប្រភេទទឹកផ្កាឈូកពីទឹកផ្កាឈូកជំ ទៅទឹកផ្កាឈូកតូចទឹកមួយចំនួន និងបន្តស្រក់ពីក្បាលទឹកផ្កាឈូកក្នុងរយៈពេលតិចជាង 2 នាទី។នេះជារឿងធម្មតាទេ ដោយសារតែទឹកមួយចំនួននៅតែមាននៅក្នុងក្បាលទឹកផ្កាឈូកហើយមិនមានអ្វីខុសប្រក្រតីចំពោះឧបករណ៍នេះទេ។

7. ក្បាលទឹកផ្កាឈូកអាចត្រូវបានកំណត់នៅទីតាំងផ្សេងគ្នា។
   a) បន្ទូរប្រដាប់មួលធ្នើរទឹកផ្កាឈូក និងធ្នើទឹកផ្កាឈូកអាចត្រូវបានលៃតម្រូវទីតាំងខ្ពស់ឬទាប។
      រឹតបន្តឹងប្រដាប់មួលរឹងធ្នើរព្យួរទឹកផ្កាឈូក
   b) ការបន្ធូរប្រដាប់មួលបន្ធូរធ្នើព្យួរទឹកផ្កាឈូក និងធ្នើរព្យួរទឹកផ្កាឈូក អាចលៃតម្រូវទៅទីតាំងឆ្វេង ឬស្តាំ។
      រឹតបន្តឹងប្រដាប់មួលរឹងធ្នើរព្យួរទឹកផ្កាឈូក
   c) ម៉ុនៃក្បាលទឹកផ្កាឈូកអាចលៃតម្រូវបានដោយផ្លាស់ទីក្បាលទឹកផ្កាឈូកឡើងលើ និងចុះក្រោម។


(a) (b) (c)

8. ការកំណត់សីតុណ្ហភាព
   <u>DH-4US1 & DH-3US1</u>
   a) សីតុណ្ហភាពទឹកផ្កាឈូកអាចត្រូវបានគ្រប់គ្រងសន្សឹមៗ ដោយការកំណត់កុងតាក់គ្រប់គ្រងថាមពលទៅទីតាំងដែលចង់បាន។
   b) ប្រសិនបើអ្នកកាច់កុងតាក់គ្រប់គ្រងថាមពលតាមទ្រនិចនាឡិកា នោះសីតុណ្ហភាពផ្កាឈូកនឹងកើនឡើងដោយឈានដល់សីតុណ្ហភាពខ្ពស់បំផុតនៅ “High” ។
   c) ប្រសិនបើកុងតាក់គ្រប់គ្រងថាមពលស្ថិតនៅទីតាំង “Off” ទឹកក្តៅនឹងស្ថិតនៅត្រឹមទុយោចូលថេរដដែល
   d) ភ្លឺងករណីដែលមានការប្រើប្រាស់ទឹកក្តៅមិនឈប់ឈរជាបន្តបន្ទាប់ ធ្វើអោយសីតុណ្ហភាពទឹកកើនឡើង នោះឧបករណ៍ចាប់ផ្តើមកសីតុណ្ហភាពឡើងវិញ ជាហេតុបណ្តាលអោយសីតុណ្ហភាពទឹកចុះត្រជាក់ជាបណ្តោះអាសន្ន



ការកំណត់សីតុណ្ហភាព

DH-4UD1 & DH-3UD1

a) សីតុណ្ហភាពទឹកផ្កាឈូកអាចត្រូវបានគ្រប់គ្រងសន្សឹមៗ ដោយចុចប៊ូតុង - ឬ + ។

b) ការចុចប៊ូតុងនីមួយៗនឹងកាត់បន្ថយ ឬបង្កើនសីតុណ្ហភាព 1 °C ។
ការចុចប៊ូតុងជាបន្តបន្ទាប់នឹងកាត់បន្ថយ ឬបង្កើនសីតុណ្ហភាពជាបន្តបន្ទាប់។

c) សីតុណ្ហភាពដែលអាចផ្លាស់ប្តូរបានទាបបំផុតគឺ 32 °C ។

d) ការចុចប៊ូតុងបន្ថែមទៀតនឹងផ្លាស់ប្តូរអេក្រង់ទៅជា "PO" ដែលជាម៉ូដបិទថាមពល
(សីតុណ្ហភាពទឹកផ្កាឈូកនឹងដូចគ្នាទៅនឹងសីតុណ្ហភាពទឹកចូល) ។

e) សីតុណ្ហភាពដែលអាចផ្លាស់ប្តូរបានខ្ពស់បំផុតគឺ 45 °C ។

f) នៅពេលដែលពាក្យ "MAX" លេចឡើងនៅអេក្រង់ថាមពល ទាមទារឱ្យមានសីតុណ្ហភាពខ្ពស់ជាង
កាត់បន្ថយរំហូរទឹកដោយបង្វិលក្បាលមួលកម្រិតបរិមាណទឹកបញ្ច្រាស់ទ្រនិចនាឡិការហូតដល់បាត់ពាក្យ "MAX" ។
(សូមមើលរូបភាពទី 1)

g) ក្នុងករណីមានការប្រើប្រាស់ជាបន្តបន្ទាប់នៅការកំណត់សីតុណ្ហភាពខ្ពស់ នោះសីតុណ្ហភាពទឹកនឹងកើនឡើង
ហើយវាអាចបណ្តាលឱ្យឧបករណ៍បង់ណើរការឡើងវិញ ដើម្បីដំណើរការសីតុណ្ហភាពទឹកឱ្យធ្លាក់ចុះជាបណ្តោះអាសន្ន។



រូបភាពទី 1

9. ការកំណត់ U-Mode

DH-4UD1 & DH-3UD1

a) មាន U-Mode ចំនួនបីប្រភេទ។
   i. ម៉ូដ Cool Down
   ii. ម៉ូដ Warm Up
   iii. Hot & Cool

b) ប្រតិបត្តិការ U-Mode នឹងចាប់ផ្តើមដោយចុចប៊ូតុង U-Mode នៅផ្ទាំងបញ្ជា។



ផ្ទាំងបញ្ជា

c) មុខងារ U-Mode នឹងប្រែប្រួលដោយចុចប៊ូតុង U-Mode ជាបន្តបន្ទាប់
(U-Mode Cool Down -> U-Mode Warm Up -> U-Mode Hot & Cool)

d) បន្ទាប់ពីជ្រើសរើសមុខងារ U-Mode នោះភ្លើងសញ្ញា Hot & Cool
នឹងបញ្ចេញពន្លឺ (ប្រហែល 3 វិនាទី) ហើយភ្លើងសញ្ញា U-Mode
ដែលបានជ្រើសរើសនឹងបំភ្លឺអាស្រ័យលើមុខងារ U-Mode
ដែលបានជ្រើសរើស។

e) នៅពេលដែលដំណើរការ U-Mode ចាប់ផ្តើម នោះភ្លើងសញ្ញា Hot & Cool
នឹងភ្លឺម្តងទៀត។



ចំណាំ៖
ខណៈពេលដែលដំណើរការ U-Mode កំពុងដំណើរការ
សីតុណ្ហភាពអេក្រង់នឹងនៅតែមាន ខណៈពេលដែលសីតុណ្ហភាពទឹកផ្កាឈូក
ពិតប្រាកដនឹងថយចុះ ឬកើនឡើង (អាស្រ័យលើមុខងារ U-Mode
ដែលបានជ្រើសរើស)។

f) មានជម្រើសមួយចំនួនសម្រាប់មុខងារ U-Mode នីមួយៗ។
សូមមើលតារាងខាងក្រោមសម្រាប់ព័ត៌មានលម្អិត។

ការតភ្ជាប់មុខងារ U-Mode៖

ម៉ឺនុយ	**ការចង្អុលបង្ហាញអេក្រង់**	**ការកំណត់**				
ម៉ូដ Cool Down	Cool Down < បំភ្លឺ > Cool < បញ្ចាំងពន្លឺ >	សីតុណ្ហភាព	លំនាំដើម	ជម្រើស [1]	ជម្រើស [2]	ជម្រើស [3]
			-2 °C	-3 °C	-4 °C	PO **ថាមពលបិទ
		ម៉ោង	លំនាំដើម	ជម្រើស [1]	ជម្រើស [2]	ជម្រើស [3]
			20 s	10 s	40 s	60 s
ម៉ូដ Warm Up	Warm Up < បំភ្លឺ > Hot < បញ្ចាំងពន្លឺ >	សីតុណ្ហភាព	លំនាំដើម	ជម្រើស [1]	ជម្រើស [2]	
			2 °C	3 °C	4 °C	
		ម៉ោង	លំនាំដើម	ជម្រើស [1]	ជម្រើស [2]	ជម្រើស [3]
			20 s	10 s	40 s	60 s
ម៉ូដ Hot & Cool	Hot & Cool < បំភ្លឺ > Hot & Cool < បញ្ចាំងពន្លឺ >	សីតុណ្ហភាព	លំនាំដើម	ជម្រើស [1]	ជម្រើស [2]	ជម្រើស [3]
			-4 °C	-3 °C	-2 °C	PO **ថាមពលបិទ
		ម៉ោង	លំនាំដើម	ជម្រើស [1]	ជម្រើស [2]	
			Hot៖ 40 s ; Cool៖ 30 s	Hot៖ 30 s ; Cool៖ 20 s	Hot៖ 50 s ; Cool៖ 40 s	

g) ការកំណត់សីតុណ្ហភាព U-Mode និងកម្មវិធីកំណត់ម៉ោង។

ជំហាន		ដើម្បីធ្វើ	អេក្រង់ LCD	ការកត់សម្គាល់	
①	ចូលការកំណត់ U-Mode	ចុចប៊ូតុង Set ឱ្យយូររហូតដល់ "-2" លេចឡើងនៅសីតុណ្ហភាពបង្ហាញ។	ឥឡូវនេះនៅក្នុង "Cool Down" U Mode 	U-Mode ផ្សេងទៀត	ចុចប៊ូតុង U-Mode ដើ
				Warm Up	1 ដង។
				Hot & Cool	2 ដង។
②	ការកំណត់សីតុណ្ហភាព	ចុចប៊ូតុង + ឬ - ដើម្បីកំណត់សីតុណ្ហភាព។ ចុច Set ប៊ូតុងដើម្បីបញ្ជាក់។	សូចនាករកម្មវិធីកំណត់ម៉ោង "20" នឹងភ្លឺ។ 	U-Mode	ម៉ោង
				Cool Down	20
				Warm Up	20
				Hot & Cool	H: 40; C:30 (ជាដម្រើស)
③	ការកំណត់ម៉ោង	ចុចប៊ូតុង + ឬ - ដើម្បីកំណត់ពេលវេលា។		ការចង្អុលបង្ហាញកម្មវិធីកំណត់ម៉ោងនឹងបន្តបញ្ចេញពន្លឺកំឡុងពេលជ្រើសរើស។	
		ចុច Set ប៊ូតុងដើម្បីបញ្ជាក់។		ការបង្ហាញនឹងក្លាយជាលំនាំដើមបន្ទាប់ពីបញ្ជាក់ការកំណត់កម្មវិធីកំណត់ម៉ោង។	
④	បញ្ចូលមុខងារ U-Mode	ចុចប៊ូតុង U-Mode ទៅតាម U-Mode ដែលចង់បាន។		របៀប U-Mode ដែលបានជ្រើសរើសជាមួយនឹងការកំណត់សីតុណ្ហភាពថ្មី និងកម្មវិធីកំណត់ម៉ោងនឹងបង្ហាញឡើង	

10. ការកំណត់ U-Memory

DH-4UD1 & DH-3UD1

a) មុខងារ U-Memory អាចត្រូវបានជ្រើសរើសតាមរយៈការចុចប៊ូតុង U-Memory ។

b) U-Memory បើកឱ្យអ្នកប្រើប្រាស់កត់ត្រា រំលឹក និងលុបទិន្នន័យរហូតដល់អង្គចងចាំចំនួនបី។

ជំហាន	ដើម្បីធ្វើ	អេក្រង់ LCD	ការកត់សម្គាល់
កំណត់ត្រាទិន្នន័យ U-Memory	ចុចប៊ូតុង U-Memory [1 / 2 / 3] ឱ្យជាប់រហូតទាល់តែលេខ U-Memory បញ្ចេញពន្លឺ។		នៅពេលដែលលេខ U-Memory បំភ្លឺ ទិន្នន័យនឹងត្រូវបានកត់ត្រា។
ការរំលឹកទិន្នន័យ U-Memory	ចុចប៊ូតុងមួយនៃប៊ូតុងកំណត់ U-Memory [1 / 2 / 3]		លេខ U-Memory នឹងបញ្ចេញពន្លឺ។
ការលុបទិន្នន័យ U-Memory	ចុចប៊ូតុង U-Memory [1 / 2 / 3] ឱ្យជាប់រហូតទាល់តែលេខ U-Memory ជាត់។		លេខ U-Memory ជាត់។ (ការចង្អុលបង្ហាញនៅលើអេក្រង់ LCD នឹងភ្លឺបន្តិចៗ មុនពេលលេខ U-Memory ជាត់ ទិន្នន័យនឹងត្រូវបានលុប)។

11. ការកំណត់ម៉ោង។

DH-4UD1 & DH-3UD1

i. ចុចប៊ូតុង Set ។
ការចង្អុលបង្ហាញពេលវេលានឹងបញ្ចាំងពន្លឺ។

ii. ចុចប៊ូតុង + ឬ - ដើម្បីកំណត់ពេលវេលា។

iii. ចុចប៊ូតុង Set ដើម្បីបញ្ជាក់ការកំណត់ពេលវេលាថ្មី។ ការចង្អុលបង្ហាញពេលវេលាថ្មីនឹងប៉ះភ្លឺឡើង។

ការកែតម្រូវអត្រារំហូរទឹក

1. របៀបលៃតម្រូវរំហូរទឹកជាអតិបរមា។

ជំហានទី 1 ៖ រុញគន្លឹះរុញបើក-បិទ ហើយជ្រើសរើសប្រភេទ ជាញ់ទឹកចេញឱ្យជំនៅលើក្បាលទឹកផ្កាឈូកដោយប្រើគន្លឹះជ្រើសរើសទឹកជាញ់ (សូមមើលរូបភាពទី 1)

ជំហានទី 2 ៖ មួល "បិទ" វ៉ាល់បើកបិទទឹកមេ។

ជំហានទី 3 ៖ បង្វិលក្បាលទឹកផ្កាឈូកឡើងលើនៅកម្ពស់ចង្កេះ។

ជំហានទី 4 ៖ បង្វិលក្បាលមួលបរិមាណទៅទីតាំងកម្រិតបរិមាណអតិបរមា (សូមមើលរូបភាពទី 2) ។

ជំហានទី 5 ៖ មួល "បើក" វ៉ាល់បើកបិតទឹកមេយឺតៗ ហើយលៃតម្រូវកម្ពស់ទឹកជាញ់ (H) នៃផ្កាឈូក។
វាត្រូវបានណែនាំឱ្យលៃតម្រូវកម្ពស់ទឹកជាញ់ (H) នៅ 35 សង់ទីម៉ែត្រ ~ 45 សង់ទីម៉ែត្រ (ប្រហែល 3 លីត្រ / នាទី) ។
ប្រសិនបើកម្ពស់ទឹកជាញ់ (H) ខ្ពស់ពេក សិតុណ្ហភាពទឹកក្តៅនឹងធ្លាក់ចុះ ដោយសារអត្រារំហូរឡើងលើស។

ចំណាំ:
1. **យកចិត្តទុកដាក់លើសីតុណ្ហភាពទឹកផ្កាឈូកនៅពេលបន្តយបរិមាណទឹក។**
សីតុណ្ហភាពទឹកផ្កាឈូកនឹងឡើងក្តៅខ្លាំង ប្រសិនបើអត្រារំហូរទឹកទាបពេក។
2. **ក្បាលមួលកម្រិតបរិមាណទឹកស្ថិតនៅទីតាំងអតិបរមានៅដំណាក់កាលនេះ: (សូមមើលជំហានទី 4) ។**
សូមលៃតម្រូវអត្រាល់ហូរសមស្របដោយវាទៅតាម ដោយប្រើប៊ូតុងកម្រិតបរិមាណទឹក ដោយបង្វិលវាតាមទិសដៅបញ្ច្រាសទ្រនិចនាឡិកា។



ការថែទាំ

⚠ ការព្រមាន

បិទឧបករណ៍បំបែកសៀគ្វីតូច (MCB) មុនពេលធ្វើការជួសជុលណាមួយ ដើម្បីជៀសវាងគ្រោះថ្នាក់ពីការរងក់ចរន្តអគ្គិសនី។

1. ការសម្អាតតួឧបករណ៍។

ត្រូវប្រាកដថាបិទ "បិទ" ឧបករណ៍បម្លែងសៀគ្វីខ្នាតតូច (ឌីហ្សង់ទ័រ) ជាមុន។

1) សម្អាតវាដោយប្រើប្រាស់ក្រណាត់សើម
2) កុំប្រើប្រាស់សារធាតុបង់ហ្សែន សាំងលាយថ្នាំលាបពណ៌ សាប៊ូបោកខោអាវ ទឹកសាវែល ។ល។
3) មិនត្រូវជាញ់ទឹកចូលក្នុងឧបករណ៍ ឬដាក់កន្សែងទទឹកសើមនៅលើឧបករណ៍។
4) ត្រូវប្រាកដថាប្រើក្រណាត់ដែលសមរម្យដើម្បីសម្អាតផ្ទៃខាងមុខ ដើម្បីជៀសវាងស្នាមឆ្លុក។

2. ការសម្អាតក្បាលទឹកផ្កាឈូក។

1) សម្អាតក្បាលទឹកផ្កាឈូករបស់ក្បាលផ្កាឈូកដោយប្រើប្រាស់ទន់ម្តងម្កាល។ (ណែនាំសម្អាតម្តងក្នុងមួយសប្តាហ៍) ។



3. ការសម្អាតធុងចម្រោះទឹក (ធុងចម្រោះទឹកគឺនៅជាប់ដងដៃកាន់តម្រង) ។

លាងសម្អាតតម្រងរបស់ធុងចម្រោះទឹកជាមួយទឹកម្តងក្នុងមួយសប្តាហ៍។
លាងសម្អាតធុងចម្រោះទឹក នៅពេលដែលទឹកក្តៅមិនត្រូវបានទាញចេញជាធម្មតាទេ។

វិធីសម្អាត និងដំឡើងធុងចម្រោះទឹក។

① បិទវ៉ាល់បើកបិតទឹកមេ។



② បង្វិលក្បាលមួលកម្រិតបរិមាណទឹកតាមទ្រនិចនាឡិកា ប្រសិនបើវាប្លុកក្បាលមួលតម្រងចម្រោះ។
បង្វិលក្បាលមួលតម្រងចម្រោះបញ្ច្រាសទ្រនិចនាឡិកា ហើយទាញវាចេញ។



③ សម្អាតធុងចម្រោះទឹក។



⚠ បម្រុងប្រយ័ត្ន

សូមប្រាកដថា O-រឹងមិនត្រូវបានដោះចេញទេ ហើយស្ថិតនៅឆ្ងាយពីផ្នែកផ្សេងទៀតដើម្បីជៀសវាងការលេចធ្លាយទឹក។

④ បញ្ចូលធុងចម្រោះទឹក ហើយរឹតបន្តឹងវាឱ្យបានត្រឹមត្រូវ (តាមទ្រនិចនាឡិកា) ។

⑤ បង្វិលក្បាលមួលកម្រិតបរិមាណទឹកទៅទីតាំងដើមរបស់វា ដោយផ្អែកលើការកែតម្រូវអត្រាហូរទឹកនៅទំព័រ KH9 ។



ដំណោះស្រាយ

1. ពិនិត្យមើលចំណុចខាងក្រោមជាមុនសិន មុនពេលស្នើសុំជួសជុល។

សញ្ញា	ចំណុចដែលត្រូវពិនិត្យ
ការបង្ហាញកំហុស E3 បញ្ចេញពន្លឺនៅពេលបង្ហាញសម្រាប់ម៉ូដែល DH-4UD1 និង DH-3UD1 ។	1. កំណត់ការកំណត់ឡើងវិញដោយបិទ ហើយបើកម្តងទៀតដោយចុចប៊ូតុងបើក-បិទ។
ទឹកមិនហូរ ឬសធម្មតា	1. ពិនិត្យមើលធុងចម្រោះទឹក។ សម្អាតតម្រងប្រសិនបើវាស្ទះដោយស្មាមប្រឡាក់ និងកខ្វក់ (សូមមើលការសម្អាតឯកតាតម្រងនៅទំព័រ KH9) ។ 2. ពិនិត្យក្បាលទឹកផ្កាឈូក និងបន្ទះទឹកផ្កាឈូក។ លាងសម្អាតក្បាលទឹកផ្កាឈូក និងបន្ទះទឹកផ្កាឈូក ប្រសិនបើវាត្រូវបានស្ទះដោយភាពកខ្វក់ (សូមមើលការសម្អាតក្បាលទឹកផ្កាឈូកនៅទំព័រ KH9) ។
ទឹកមិនក្តៅ (មិនមានការផ្គត់ផ្គង់ភ្លើងអគ្គិសនីទៅក្នុងធុងកម្តៅទឹក)។	1. ត្រូវប្រាកដថាចុចកុងតាក់បើក-បិទ ដែលស្ថិតនៅទីតាំង "បើក" ។ 2. ត្រូវប្រាកដថាកំណត់ដងថ្លឹង ELB ឡើងវិញ មិនរអិលចុះក្រោមទេ។ រុញកំណត់ដងថ្លឹង ELB ឡើងវិញ ដើម្បីកំណត់ ELB ឡើងវិញ (សូមមើលប្រតិបត្តិការសាកល្បងនៅទំព័រ KH15) ។ 3. ត្រូវប្រាកដថាចុចបើកលើកុងតាក់បើក/បិទ DP (ប៉ូលពីរ)។ 4. ត្រូវប្រាកដថាត្រូវប្តូរនៅលើឧបករណ៍បម្លែងសៀគ្វីខ្នាតតូច (ប៉ូលពីរ) ។
មិនមានទឹកហូរចេញពីក្បាលទឹកផ្កាឈូកទាល់តែសោះ។	1. ពិនិត្យមើលវ៉ាល់ទឹកមេ។ បើក “បើក” វ៉ាល់ទឹកមេ ប្រសិនបើវាត្រូវបានបិទ (សូមមើលរបៀបប្រើនៅទំព័រ KH6) ។ 2. ពិនិត្យមើលប៊ូតុងបើក-បិទ។ ប្រសិនបើផ្ទាំង LCD នៅតែភ្លឺ "បិទ" ។ សូមកុំប្រើឧបករណ៍ ហើយទាក់ទងភ្នាក់ងារចែកចាយដែលទទួលសិទ្ធិជាបន្ទាន់។
ទឹកមិនក្តៅគ្រប់គ្រាន់ទេ។	1. ពិនិត្យមើលការកែតម្រូវអត្រាហូរទឹកនៅទំព័រ ដូចក្នុងទំព័រ KH9 ។

2. ប្រសិនបើភាពមិនប្រក្រតីដូចបានរៀបរាប់ខាងក្រោមត្រូវបានរកឃើញអំឡុងពេលប្រើប្រាស់ សូមកុំប្រើឧបករណ៍ ហើយទាក់ទងភ្នាក់ងារចែកចាយដែលទទួលសិទ្ធិជាបន្ទាន់។
   - ការជ្រាបទឹក។
   - មិនមានទឹកហូរ។
   - សីតុណ្ហភាពទឹកមិនអាចគ្រប់គ្រងបាន
   - អេក្រង់ LCD មិនចេញអក្សរ



3. ការជួសជុលគឺទាមទារអោយមានអ្នកជំនាញគ្រប់គ្រាន់ កុំព្យាយាមជួសជុលឧបករណ៍ដោយខ្លួនឯង។

4. សម្រាប់ម៉ូដែល DH-4UD1 និង DH-3UD1 ក្នុងករណីមានកំហុសជាបន្តបន្ទាប់ (E1, E2 ឬ E3 នឹងមានពន្លឺនៅអេក្រង់បង្ហាញសីតុណ្ហភាព) សូមកុំប្រើឧបករណ៍ ហើយទាក់ទងភ្នាក់ងារចែកចាយដែលទទួលសិទ្ធិជាបន្ទាន់។

លក្ខណៈបច្ចេកទេស

លេខម៉ូដែល	DH-4UD1	DH-4US1	DH-3UD1	DH-3US1
កម្លាំងវ៉ុល	220 V a.c. 50 Hz			
ការប្រើប្រាស់ថាមពល	4800 W		3800 W	
ឧបករណ៍ត្រួតពិនិត្យសីតុណ្ហភាពអគ្គិសនី	សីតុណ្ហភាពទឹកចូល PO (បិទ), 32 °C - 45 °C	-	សីតុណ្ហភាពទឹកចូល PO (បិទ), 32 °C - 45 °C	-
ទូកាប៊ីនបញ្ជាភ្លើង	-	សីតុណ្ហភាពទឹកចូល (បិទ), 4800 W	-	សីតុណ្ហភាពទឹកចូល (បិទ), 3800 W
អប្បបរិមា សម្ពាធទឹក	9.8 kPa / 0.1 kgf/cm² / 1.42 psi			
អតិបរមា សម្ពាធទឹក	380 kPa / 3.87 kgf/cm² / 55 psi			
វិមាត្រ	385 (H) mm x 210 (W) mm x 78 (D) mm			
ទម្ងន់	2.0 kg	1.6 kg	1.9 kg	1.5 kg
ប្រព័ន្ធច្រកចេញ	ប្រព័ន្ធចំណុចតែមួយ (បើកច្រកចេញ)			

⚠ ការព្រមាន

- **ទំហំត្រឹមត្រូវនៃខ្សែអាចពាក់បាន និងខ្សែអគ្គិសនីត្រូវតែតម្លើង ដើម្បីជៀសវាងការប៉ះភាយផ្សែង និងគ្រោះថ្នាក់អគ្គិភ័យ។**
- **ក្នុងអំឡុងពេលដំណើរការដំឡើង សូមប្រាកដថាការផ្គត់ផ្គង់អគ្គីសនី និងទឹកត្រូវបានចុច "បិទ" ។**
- **ទឹកថ្នាំឈូកក្នុងផ្ទះត្រូវតែភ្ជាប់ជាអចិន្ត្រៃយ៍ទៅនឹងការផ្គត់ផ្គង់អគ្គិសនីតាមរយៈកុងតាក់បើក/បិទ DP (បូលពីរ) ដែលមានទំនាក់ទំនងបំបែកយ៉ាងហោចណាស់ 3 mm នៅគ្រប់បង្គោលទាំងអស់ដែលបានបញ្ចូលក្នុងខ្សែភ្លើងថែរ។ កុងតាក់នេះត្រូវតែអាចកំណត់អត្តសញ្ញាណបានយ៉ាងច្បាស់ ប៉ុន្តែនៅឆ្ងាយពីមនុស្សដែលប្រើអាងងូតទឹក ឬទឹកថ្នាំឈូក។**

- **ឧបករណ៍នេះត្រូវតែភ្ជាប់ខ្សែដី។**
  - ការតភ្ជាប់ខ្សែដីមិនត្រឹមត្រូវអាចបង្កឱ្យមានការឆក់ចរន្តអគ្គិសនី។

- **កុំដំឡើងគ្រោងបង្គំចម្រោះទឹកនៅកន្លែងបញ្ចេញទឹក ទឹកដែលចូលមិនអាចចម្រោះបាន និងមិនអនុញ្ញាតឱ្យភាគល្អិតចម្លែកចូលក្នុងឧបករណ៍បាន។ វានឹងធ្វើឱ្យឧបករណ៍ឡើងក្តៅ និងក្លាយទឹកថ្នាំឈូកស្អុះ។**
- **កុំតម្លើង ដក ឬតម្លើងឧបករណ៍ឡើងវិញដោយខ្លួនឯង។**
  - ការតម្លើងមិនត្រឹមត្រូវនឹងបណ្តាលឱ្យជ្រាបទឹក ឆក់ ឬឆេះ។ ការតម្លើង និងការតខ្សែភ្លើងត្រូវតែធ្វើឡើងដោយបុគ្គលិកដែលមានសមត្ថភាព។
- **កុំចែករំលែកបំពង់ចូល និងចេញរបស់ធុងទឹកចម្រោះទឹកថ្នាំឈូកជាមួយកន្លែងប្រកចេញផ្សេងទៀត។**
  - សម្ពាធអាចធ្លាក់ចុះដោយសារតែទឹកត្រូវបានទាញចេញនៅចំណុចផ្សេងទៀត។ សីតុណ្ហភាពទឹកថ្នាំឈូកអាចក្តៅខ្លាំង។



⚠ បម្រុងប្រយ័ត្ន

- **ខ្សែដែលអាចបត់បែនបានត្រូវតែចូលទៅក្នុងឧបករណ៍តាមរយៈចំណុចដែលបានកំណត់តែប៉ុណ្ណោះ (កុំបង្កើតរន្ធបន្ថែម)។**

មុនពេលតម្លើង

1. **ត្រូវប្រាកដថារំហូរទឹកមានសម្ពាធ។**

អប្បបរិមា សម្ពាធទឹក	៖	9.8 kPa / 0.1 kgf/cm² / 1.42 psi
អតិបរមា សម្ពាធទឹក	៖	380 kPa / 3.87 kgf/cm² / 55 psi

- របៀបវាស់សម្ពាធទឹកដូចក្តាងរូប។ ទឹកគួរហូរចេញពីទុយោ 2.0 m ពីលើវាល់ទឹកមេ។



ចំណាំ៖
នៅពេលដកឧបករណ៍ចេញពីកញ្ចប់ អាចមានទឹកខ្លះនៅខាងក្នុង។
នេះជារឿងធម្មតាទេ ដោយសារឧបករណ៍ត្រូវបានសាកល្បងក្នុងអំឡុងពេលដំណើរការផលិត។

របៀបតម្លើង

⚠ ការព្រមាន

ក្នុងអំឡុងពេលដំណើរការដំឡើង សូមប្រាកដថាការផ្គត់ផ្គង់អគ្គីសនី និងទឹកត្រូវបានចុច "បិទ" ។



រូបភាពទី 1

រូបភាពទី 2

1. កន្លែងដែលត្រូវដំឡើងឧបករណ៍។
- ត្រូវប្រាកដថាតម្លើងឧបករណ៍នៅលើជញ្ជាំងដូចបានបង្ហាញក្នុងរូបភាពទី 1 (ក្នុងលក្ខខណ្ឌបញ្ឈរតែប៉ុណ្ណោះ) ។
- កុំតម្លើងឧបករណ៍ឱ្យឆ្ងាយពីផ្ទៃជញ្ជាំងដូចបង្ហាញក្នុងរូបភាពទី 2 ។
- ឧបករណ៍ត្រូវតម្លើងនៅកម្ពស់ 1.5 m ~ 1.7 m ពីលើកំរាលឥដ្ឋ។

2. របៀបដកបន្ទះខាងមុខចេញ។

DH-4UD1 & DH-3UD1

① ដោះវីសនៅផ្នែកខាងក្រោមនៃឧបករណ៍។

② ដោះបន្ទះខាងមុខដោយលើកផ្នែកខាងក្រោមឡើង ហើយបន្ទាប់មកដោះផ្នែកខាងលើ។



DH-4US1 & DH-3US1

① ត្រូវប្រាកដថាកុងតាក់គ្រប់គ្រងថាមពលស្ថិតនៅក្នុងលក្ខខណ្ឌ “Off” ។

② ដោះវីសនៅផ្នែកខាងក្រោមនៃឧបករណ៍។

③ លើកកុងតាក់គ្រប់គ្រងថាមពលឡើង ដើម្បីធ្វើឱ្យវាទំនេរ (កុងតាក់គ្រប់គ្រងថាមពលត្រូវបានភ្ជាប់ជាមួយ “VR Shaft” នៅខាងក្នុងឧបករណ៍) ។
សូមប្រាកដថាកុងតាក់គ្រប់គ្រងថាមពលមិនត្រូវបានផ្តាច់ចេញពីបន្ទះខាងមុខទេ។

④ ដោះបន្ទះខាងមុខដោយលើកផ្នែកខាងក្រោមឡើង ហើយបន្ទាប់មកដោះផ្នែកខាងលើ។

ចំណាំ៖
កុងតាក់គ្រប់គ្រងថាមពលដែលភ្ជាប់ទៅនឹងបន្ទះខាងមុខ។



កុងតាក់គ្រប់គ្រងថាមពល



3. របៀបភ្ជាប់ម៉ាស៊ីនទឹកក្តៅអគ្គិសនីតាមផ្ទះ

① ចម្ងាយរបស់ឧបករណ៍ត្រូតែមានលើសពី 250 mm នៅខាងស្តាំនិងខាងឆ្វេងនៃជញ្ជាំង។

② ធ្វើរន្ធចំនួន 4 នៅក្នុងជញ្ជាំងដោយប្រើដែកស្វាន។ ទីតាំងនៃទីតាំងរន្ធដូចដែលបានបង្ហាញនៅក្នុងគំរូការតម្លើងដែលបានផ្តល់ឱ្យ។

③ ដាក់តាកេចូលទៅក្នុងរន្ធ



រូបភាពទី 1



④ នាំខ្សែដែលអាចបត់បែនបានទៅការក់ណាត់តាមរយៈផ្នែកទី 1 ឬទី 2 ដូចដែលបានបង្ហាញខាងក្រោមសម្រាប់ដំណើរការខ្សែភ្លើង។

ផ្នែកទី 1៖


ចំណុចចូលខ្សែដែលអាចបត់បែនបាន

ផ្នែកទី 2៖



⚠ បម្រុងប្រយ័ត្ន

ខ្សែដែលអាចបត់បែនបានត្រូវតែចូលទៅក្នុងឧបករណ៍តាមរយៈចំណុចដែលបានកំណត់តែប៉ុណ្ណោះ (កុំបង្កើតរន្ធបន្ថែម)។

⑤ • ម៉ោនឧបករណ៍នៅលើជញ្ជាំងដោយប្រើវីស 4 ។
• បញ្ចូលវីសនីមួយៗចូលទៅក្នុងតាកេពីរខាងលើតាមរយៈរន្ធវីសនៅលើបន្ទះខាងក្រោយ។
• បន្ទាប់ពីរឹតបន្តឹងវីសខាងលើទាំងពីរ សូមរឹតបន្តឹងវីសទាំងពីរដែលនៅសល់។



⑥ សូមប្រាកដថាឧបករណ៍ត្រូវបានភ្ជាប់យ៉ាងតឹងនៅលើជញ្ជាំងដោយអង្រួនវាទៅឆ្វេង និងស្តាំ។

ចំណាំ:
បន្ទះខាងក្រោយត្រូវតែភ្ជាប់ជាមួយនឹងវីស 4 ។



4. ខ្សែអគ្គិសនី។

⚠ **ការព្រមាន**	**ទំហំត្រឹមត្រូវនៃខ្សែអាចពត់បាន និងខ្សែអគ្គិសនីត្រូវតែតម្លើងដើម្បីជៀសវាងការបំភាយផ្សែង និងគ្រោះថ្នាក់អគ្គិភ័យ។**
⚠ **ការព្រមាន**	**ទឹកផ្តាឈូកក្នុងផ្ទះត្រូវតែភ្ជាប់ជាអចិន្ត្រៃយ៍ទៅនឹងការផ្គត់ផ្គង់អគ្គិសនីតាមរយៈកុងតាក់បើក/បិទ DP (ប៉ូលពីរ) ដែលមានទំនាក់ទំនងបំបែកយ៉ាងហោចណាស់ 3 mm នៅគ្រប់បង្គោលទាំងអស់ដែលបានបញ្ចូលក្នុងខ្សែភ្លើងថេរ។ កុងតាក់នេះត្រូវតែអាចកំណត់អត្តសញ្ញាណបានយ៉ាងច្បាស់ ប៉ុន្តែនៅឆ្ងាយពីមនុស្សដែលប្រើអាងងូតទឹកឬទឹកផ្តាឈូក។**

① **តម្រង់ខ្សែដែលអាចបត់បែនបានភ្ជាប់ទៅនឹងកន្លែងដោត ELB នៅខាងក្នុងឧបករណ៍: 2.5 mm² ខ្សែភ្លើងដែលអាចបត់បែនបានដែលមានខ្សែភ្លើងខាងក្នុង 3 ។**

② **ដោះវីសចេញពីប្រដាប់ដាក់ខ្សែ ហើយភ្ជាប់ខ្សែដែលអាចបត់បែនបាន។ កាត់មុខខ្សែ (ច្រឹបមុខខ្សែ)។ ភ្ជាប់ខ្សែភ្លើង (L) និងខ្សែគ្មានកំណត់ (N) ទៅនឹងខ្សែភ្លើង ELB (L,N) ខ្សែដីទៅចំណុចដីជាមួយនឹងកម្លាំងបង្ចិល 1 N•m (10 kgf.cm) ។ ភ្ជាប់ប្រដាប់ដាក់ខ្សែទៅទីតាំងរបស់វាដើម្បីកៀបខ្សែដែលអាចបត់បែនបាន។**







③ **ភ្ជាប់ខ្សែភ្លើងក្នុងប៉ូលដែលត្រឹមត្រូវ (L,N) ។**
• ភ្ជាប់ខ្សែភ្លើងដែលខុសប៉ូល (L,N) បណ្តាលឱ្យមានស្ថានភាពមិនប្រក្រតីដែលអាចនាំឱ្យលេចធ្លាយអគ្គិសនី ការឆាបឆេះ ជាដើម។
• មុនពេលតខ្សែ សូមពិនិត្យមើលប៉ូល (L,N) ជាមួយនឹងជួរតេស្តរ៉ូលភ្លើង ឬរ៉ូលម៉ែត្រ ដោយភ្ជាប់កន្លែងដោតមួយនៃម៉ែត្រទៅជាប់នឹងដី ខណៈមួយទៀតទៅកន្លែងដោតផ្គត់ផ្គង់ថាមពលមួយ។
• នៅពេលដែលទ្រនិចរបស់ម៉ែត្រផ្លាតយ៉ាងខ្លាំង ប៉ូលនៃកន្លែងដោតផ្គត់ផ្គង់ថាមពលគឺ 'L' ។



④ **បង្គោលដី។**

⚠ **ការព្រមាន**	**ឧបករណ៍នេះត្រូវតែតភ្ជាប់ខ្សែដី។** ការតភ្ជាប់ខ្សែដីមិនត្រឹមត្រូវអាចបង្កឱ្យមានការឆក់ចរន្តអគ្គិសនី។

• ឧបករណ៍នេះត្រូវតែតភ្ជាប់ខ្សែដី។
• នីតិវិធីភ្ជាប់បង្គោលដី។ ជ្រើសរើសកន្លែងសមរម្យដើម្បីកប់បង្គោលដី ដែលជាជម្រើស (DQ-6H) យ៉ាងហោចណាស់ 70 cm ខាងក្រោមផ្ទៃដី។
• ត្រូវប្រាកដថា ភាពធន់នឹងដីមានតិចជាង 100 Ω ។ ប្រសិនបើវាមិនមែនទេ រុញ របាឱ្យកាន់តែជ្រៅទៅក្នុងដី ឬប្រើ 2 ឬ 3 របា។



5. នីតិវិធីតម្លើងបំពង់។

① ដាក់ការវេចខ្ចប់កៅស៊ូរវាងតួតម្រង និងបំពង់ដែលអាចបត់បែនបាន។
កុំប្រើស្អិតបិទបំពង់។
<u>រឹតបន្តឹងវាដោយប្រើកូនសោរសម្រាប់មួលខ្ចៅឬប៊ូឡុងឱ្យបានរឹងមាំ។</u>

② ដាក់ការវេចខ្ចប់កៅស៊ូរវាងបង្គុំតួខ្លួនតម្រង និងតួមេ។
កុំប្រើស្អិតបិទបំពង់។ **<u>រឹតបន្តឹងវាដោយដៃឱ្យបានមាំ។</u>**

③ ដាក់ការវេចខ្ចប់កៅស៊ូរវាងបំពង់ទឹកផ្កាឈូក និងតួមេ។
កុំប្រើស្អិតបិទបំពង់។ **<u>រឹតបន្តឹងវាដោយដៃឱ្យបានមាំ។</u>**

④ ដាក់ការវេចខ្ចប់កៅស៊ូរវាងបំពង់ទឹកផ្កាឈូក និងក្បាលទឹកផ្កាឈូក។
កុំប្រើស្អិតបិទបំពង់។ **<u>រឹតបន្តឹងវាដោយដៃឱ្យបានមាំ។</u>**

⑤ តួខ្លួនតម្រងតួរតែត្រូវបានដាក់នៅទិសខាងមុខនៃឧបករណ៍។





⚠ ការព្រមាន

កុំចែករំលែកបំពង់ចូល ឬចេញរបស់ធុងទឹកចម្រោះទឹកផ្កាឈូកជាមួយកន្លែងប្រកបចេញផ្សេងទៀត។
សម្ពាធអាចធ្លាក់ចុះដោយសារតែទឹកត្រូវបានទាញចេញនៅចំណុចផ្សេងទៀត។
សីតុណ្ហភាពទឹកផ្កាឈូកអាចក្តៅខ្លាំង។

⚠ បម្រុងប្រយ័ត្ន

ជៀសវាងការប្រើប្រាស់ទឹកខ្វក់ ព្រោះវាអាចប៉ះពាល់ដល់ដំណើរការកម្តៅ និងសមាសធាតុផ្សេងទៀត។

ចំណាំ៖	ត្រូវប្រាកដថាមិនមានទឹកលេចធ្លាយចេញពីការតភ្ជាប់បំពង់។
ចំណាំ៖	នៅពេលដែលការត្រូវបានប្រើសម្រាប់ការតភ្ជាប់បំពង់ខាងក្រៅ ត្រូវតែរង់ចាំឱ្យការសួត មុនពេលដំណើរការសាកល្បងជាមួយនឹងទឹក។



6. របៀបភ្ជាប់បន្ទះខាងមុខ។

<u>DH-4UD1 & DH-3UD1</u>

① បិទបន្ទះខាងមុខរបស់ធុងចម្រោះទឹកតាមលំដាប់ដូចបានបង្ហាញ (បិទពីលើចុះក្រោម)។

② ភ្ជាប់វីសនៅផ្នែកខាងក្រោមនៃឧបករណ៍។

ចំណាំ៖
កុំចុចប៊ូតុងតេស្ត ELB អំឡុងពេលភ្ជាប់បន្ទះខាងមុខ។



<u>DH-4US1 & DH-3US1</u>

① ត្រូវប្រាកដថា កុងតាក់ក្រប់ក្រងថាមពលនៅលើបន្ទះខាងមុខ ហើយវាស្ថិតនៅទីតាំង “Off” ។

② ត្រូវប្រាកដថា ទីតាំងប្រដាប់កាត់ “D-Cut” នៃដង VR មានទីតាំងនៅដូចបានបង្ហាញ។

③ បិទបន្ទះខាងមុខរបស់ធុងចម្រោះទឹកតាមលំដាប់ដូចបានបង្ហាញ ។

④ រុញប៊ូតុងក្រប់ក្រងថាមពលចូលទៅក្នុងរហូតទាល់តែវាបញ្ចូលពេញ
<កុងតាក់ក្រប់ក្រងថាមពលមិនអាចបញ្ចូលបានទេ ប្រសិនបើដំហានទី ① និងដំហានទី ② មិនត្រូវបានបំពេញតាមនោះ> ។

⑤ ភ្ជាប់វីសនៅផ្នែកខាងក្រោមនៃឧបករណ៍។



ចំណាំ៖
1. កុំចុចប៊ូតុងតេស្ត ELB អំឡុងពេលភ្ជាប់បន្ទះខាងមុខ។
2. កុំប្រើកម្លាំងខ្លាំងពេកពេលដែលបញ្ចូលប៊ូតុងក្រប់ក្រងថាមពលអំឡុងពេលភ្ជាប់បន្ទះខាងមុខ ព្រោះវានឹងធ្វើឱ្យខូចកុងតាក់នៅខាងក្នុងឧបករណ៍។



7. ការដំឡើងផ្នើញ្យរទឹកផ្កាឈូក។

① តម្លើងទម្របង្កាន់ដៃ ដូច្នេះក្សាលទឹកផ្កាឈូក មិនខ្ពស់ជាងផ្នែកខាងលើនៃឧបករណ៍។

ត្រូវប្រាកដថា កម្រិតជញ្ជាំងត្រូវតែដូចគ្នា ទៅនឹងទឹកាំងដែលភ្ជាប់ទម្របង្កាន់ដៃ។ ប្រសិនបើជញ្ជាំងមិនទៅកម្រិតដូចគ្នាទេ សូមប្រើប្រដាប់រក្សាតម្លាត (មិនរួមបញ្ចូល) ដើម្បីភ្ជាប់ត្រឿងបន្លាស់។



② រុញកម្របទម្របង្កាន់ដៃ (ក្នុងទិសដៅផ្កាច់) ទៅខាងក្រោយតែមជញ្ជាំង ដោយប្រើឧបករណ៍សមរម្យ ដើម្បីផ្កាច់វាចេញពីទម្រ បង្កាន់ដៃ។



③ តម្លើងទម្របង្កាន់ដៃខាងលើនៅលើជញ្ជាំង ប៉ុន្តែមិនខ្សិខ្ពស់ជាង ឧបករណ៍ខាងលើទេ។ រឹតបន្តឹងទម្របង្កាន់ដៃ ខាងលើដោយវីស 1 ។



④ រៀបចំឧបករណ៍ផ្នើរញ្យរទឹកផ្កាឈូក និងជើងរំកិលទៅមក ដកផ្នើរញ្យរទឹកផ្កាឈូកចេញដោយបង្វិលវា (ច្រាសទ្រនិចនាឡិកា) បន្ទាប់មកតម្លើងផ្នែកតាមលេខ ①, ② និង ③ ។



⑤ រឹតបន្តឹងកន្លែងផ្នើរញ្យរទឹកផ្កាឈូកដោយប្រើក្សាលមួលផ្នើរញ្យរទឹកផ្កាឈូក។



* ផ្នើរញ្យរទឹកផ្កាឈូកនឹងទម្លាក់ចេញ បានយ៉ាងងាយនៅពេលដែលក្សាល មួលត្រូវបានបន្ធូរ។

⑥ តម្លើងទម្របង្កាន់ដៃខាងលើ និងខាងក្រោមជាមួយនឹង ជើងរំកិលទៅមកដែលបញ្ចូល ទៅក្នុងរន្ធរបស់ទម្របង្កាន់ដៃ។ រឹតទម្របង្កាន់ដៃខាងក្រោម ដោយវីស 1 ។ (ត្រូវប្រាកដថា បញ្ចូលតាកេទៅក្នុងរន្ធវីស)



⑦ ត្របទម្របង្កាន់ដៃខាងលើ និងខាងក្រោមជាមួយនឹង កម្របទម្របង្កាន់ដៃ។



⑧ កែសម្រួលផ្នើរញ្យរទឹកផ្កាឈូកនៅកម្រិតដែលត្រូវការ ហើយញ្យរផ្នើរញ្យរទឹកផ្កាឈូក ដូចដែលបង្ហាញក្នុងផ្សាក្រាមខាងក្រោម។



ដំណើរការសាកល្បង

1. • មុនពេលមួល "បើក" ការផ្គត់ផ្គង់អគ្គិសនី ត្រូវពិនិត្យមើលខ្សែភ្លើង។
   • មួល "បើក" ឧបករណ៍ប៉ប៉ែកសៀគ្វីខ្នាតតូច (MCB) និងកុងតាក់ DP បើក/បិទ (ប៉ូលពីរ) ។
   • កំណត់ ELB នៃឧបករណ៍ដើម្បី "បើក" ។ (រុញឡើងដងរុញកំណត់ឡើងវិញ ELB ប្រសិនបើវាធ្លាក់ចុះ)
   • ចុចប៉ូតុងតេស្ត ELB ។
   • វាជារឿងធម្មតាទេ ប្រសិនបើ ELB "បិទ" (ដងរុញកំណត់ឡើងវិញ ELB ធ្លាក់) ហើយរុញដងរុញកំណត់ឡើងវិញ ELB ឡើង។ យោងតាមរូបភាពដូចបានបង្ហាញ។
   • ការត្រួតពិនិត្យលើ ELB ដែលភ្ជាប់មកជាមួយ (មួយខែម្តង) ដើម្បីជៀសវាងគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់
   ដូចជាការខូចខាតទ្រព្យសម្បត្តិ ការរងរបួសធ្ងន់ធ្ងរ ឬការស្លាប់។





⚠ ការព្រមាន

ប្រសិនបើដងកុងតាក់ ELB មិនអាចកំណត់ឡើងវិញបានទេ ទោះបីជាអ្នករុញវាឡើងលើ ឬប្រសិនបើវាធ្លាក់ចុះមកវិញភ្លាមៗចុះក្រោមអំឡុងពេលប្រតិបត្តិការកំដោយ សូមកុំប្រើម៉ាស៊ីនទឹកក្តៅ ហើយទាក់ទងភ្នាក់ងារចែកចាយជាបន្ទាន់ ដើម្បីជៀសវាងគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ដូចជាការខូចខាតទ្រព្យសម្បត្តិ របួសធ្ងន់ធ្ងរ ឬការស្លាប់។ កុំជួសជុលដងកុងតាក់ ELB ដោយកម្លាំងឬបិតស្ពុតស្ពុត ជាដើម។ល។

2. • កាច់ "បើក" វ៉ាល់ទឹកមេ។
   • បង្វិលក្សាលមួលកម្រិតបរិមាណទឹកតាមទ្រនិចនាឡិកា។
   • ត្រួតពិនិត្យមើលថាតើទឹកលេចធ្លាយពីខ្សែបំពង់។

3. • ចុចដងរុញបើក-បិទម្តង ផ្ទាំង LCD (DH-4UD1 & DH-3UD1) ឬអំពូលភ្លើង ELB (DH-4US1 & DH-3US1) នឹងត្រូវបានបើកដំណើរការ ហើយទឹកចាប់ផ្តើមហូរចេញពីក្សាលទឹកផ្កាឈូក។
   • កែតម្រូវសីតុណ្ហភាពទឹក។

4. • សូមមើលព័ត៌មានលម្អិតសម្រាប់របៀបប្រើប្រាស់ និងការកែតម្រូវអត្រារំហូរទឹក នៅលើទំព័រ KH6 & KH9 ។

MEMO

MEMO

Panasonic Manufacturing Malaysia Berhad (196501000304)
No. 3, Jalan Sesiku 15/2, Section 15, Shah Alam Industrial Site,
40200 Shah Alam, Selangor Darul Ehsan, Malaysia.
http://www.panasonic.com

Printed in Malaysia
H0622Y0